Ottawa County Health Department

# សន្លឹកពតិមានសាធារណៈ

## ជំងឺអង់ត្រាក់

### តើជំងឺអង់ត្រាក់ជាអ្វី ?

ជំងឺអង់ត្រាក់ ជាជំងឺឆ្លង ដែលបណ្តាលមកពីបាក់តេរីដែលបង្កើតស្ព័រ ។ ជំងឺអង់ត្រាក់មានបីទំរង់ : ស្បែក (ប៉ះពាល់) សួត (ស្រូបចូលតាមដង្ហើម) និង ពោះវៀន ។

### តើអ្នកណាខ្លះអាចកើតជំងឺអង់ត្រាក់ ?

អង់ត្រាក់ មិនមានជាទូទៅនៅក្នុងសហរដ្ឋទេ ។ ប៉ុន្តែជួនកាល វាអាចឆ្លងលើសត្វពាហនៈ ដូចជា គោក្របី ព្រមទាំងមនុស្ស ។

### តើជំងឺអង់ត្រាក់ឆ្លងតាមរបៀបណា ?

ជំងឺអង់ត្រាក់ អាចឆ្លងតាមវិធីខាងក្រោមនេះ :

- ស្បែក (ប៉ះពាល់) : ដោយការប៉ះពាល់ជាមួយ :
    - សត្វដែលឆ្លងមេរោគ ឬ រោម ឬ ស្បែក
    - ផលិតផលធ្វើពីសត្វដែលឆ្លងមេរោគ
    - ដីដែលមានមេរោគ
- សួត (ស្រូបចូលតាមដង្ហើម)
    - ដកដង្ហើមស្រូបយកខ្យល់ដែលមានស្ព័រអង់ត្រាក់
- ពោះវៀន
    - ហូបសាច់មិនបានចំអិនល្អ របស់សត្វដែលឆ្លងមេរោគអង់ត្រាក់

ការប្រឈម ក៏អាចកើតឡើងតាមរយៈអំពើជីវភេរវកម្ម ផងដែរ ។ ការឆ្លងអង់ត្រាក់ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត កំរមានណាស់ ។

### តើអង់ត្រាក់អាចមានរោគសញ្ញាអ្វីខ្លះ ?

រោគសញ្ញារបស់អង់ត្រាក់ ប្រែប្រួលទៅតាមរបៀបនៃការឆ្លងជំងឺ ហើយជាទូទៅវាស្តែងឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ ។

*ស្បែក (ប៉ះពាល់) :* វាស្តែងឡើងជា រមាស់ មុន ដូចជាដុំពកដែលអាចមានទឹកខាងក្នុង ។ ក្នុង រយៈពេល១ ទៅ ២ ថ្ងៃ ដុំពកក្លាយទៅជាដំបៅស្បែក ដោយមានចំនុចខ្មៅចំកណ្តាល ។ កន្លែងដែលប៉ះពាល់ អាចឡើងក្រហម ហើម ហើយជាញឹកញយ វាមិនមានការឈឺចាប់ទេ ។

*សួត (ស្រូបចូលតាមដង្ហើម) :* រោគសញ្ញាដំបូង វាអាចជាផ្តាសាយធម្មតា ។ ពីរបីថ្ងៃក្រោយមក មានបញ្ហាធ្ងន់ធ្ងរក្នុងការដកដង្ហើម ។ អង់ត្រាក់ដែលឆ្លងតាមការស្រូបចូលតាមដង្ហើម ច្រើនបណ្តាលអោយស្លាប់ បើគេមិនបានព្យាបាលទាន់ពេលវេលាទេនោះ ។

*ពោះវៀន :* រោគសញ្ញាដំបូងគេ អាចមានដូចជា ចង្អោរ មិនឃ្លានអាហារ ក្អួត និងគ្រុន រួចមានឈឺនៅផ្នែកខាងក្រោមពោះ ក្អួតឈាម និងរាគធ្ងន់ធ្ងរ ។

### តើគេធ្វើរោគវិនិច្ឆ័យជំងឺអង់ត្រាក់តាមរបៀបណា ?

គេធ្វើរោគវិនិច្ឆ័យជំងឺអង់ត្រាក់តាមរយៈ ឈាម ដំបៅស្បែក ឬទឹកដែលចេញពីផ្លូវដង្ហើម ។

### តើគេព្យាបាលជំងឺអង់ត្រាក់ ដូចម្តេច ?

នៅដំណាក់កាលដំបូងនៃជំងឺ វេជ្ជបណ្ឌិតអាចព្យាបាលដោយប្រើអង់ទីប៊ីយ៉ូទិក ។ ប៉ុន្តែបើគេមិនបានព្យាបាលទេនោះ អ្នកជំងឺអាចស្លាប់ ។ បើអ្នកបានប៉ះពាល់ជាមួយផលិតផលដែលមានមេរោគ និងមានរោគសញ្ញាខាងលើ សូមទៅជួបវេជ្ជបណ្ឌិតរបស់អ្នកជាបន្ទាន់ ។

**សំរាប់ពតិមានបន្ថែមស្តីអំពី ជំងឺអង់ត្រាក់ សូមទាក់ទង :**

Ottawa County Health Department
www.miOttawa.org

Centers for Disease Control and Prevention
www.bt.cdc.gov/agent/anthrax/
ទូរស័ព្ទ : (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ : (616) 396-5266
ទូរសារ : (616) 393-5643
វិបសាយ : www.miOttawa.org